**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

Media Release

# កិច្ចសហការ និងគាំទ្រពីក្រសួងកិច្ចការនារី ធ្វើឲ្យយុទ្ធនាការ Fit for Hope ២០២២ របស់ AIA Cambodia កាន់តែធំ និងផ្សព្វផ្សាយកាន់តែទូលំទូលាយ

**ភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២២** – ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA Cambodia បានចាប់បើក យុទ្ធនាការ Fit for Hope ២០២២ ដែលជាយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ប្រចាំឆ្នាំរបស់ខ្លួន ដែលឆ្នាំនេះ AIA Cambodia ទទួលបានការគាំទ្រ និងសហការពីក្រសួងកិច្ចការនារី ដោយឈរលើគោលបំណងធំមួយ គឺបង្កើនការយល់ដឹង ផ្សព្វផ្សាយសារៈសំខាន់លើវិធានការបង្ការ និងជួយស្ត្រីកម្ពុជាឲ្យទទួលបានសុខភាពល្អ។

គួរកត់សម្គាល់ថា ពិធីបើកយុទ្ធនការនេះ ទទួលបានការចូលរួមពីគណអធិបតីដ៏ខ្ពង់ខ្ពស់ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី **លោក** Andrew Loh អគ្គនាយកប្រតិបត្តិ AIA Cambodia តំណាងមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ដៃគូអាជីវកម្ម បុគ្គលិកនិងទីប្រឹក្សាផែនការជីវិត AIA Cambodia។

យុទ្ធនាការនេះមានរយៈពេលមួយខែ ដែលនឹងផ្តោតលើការរៃអង្គាសថវិកាដើម្បីគាំទ្រដល់មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម សម្រាប់ផ្តល់ការពិនិត្យជំងឺប្រកបដោយគុណភាពខ្ពស់ ការពិគ្រោះ និងការព្យាបាលជំងឺមហារីកសុដន់ ក៏ដូចជាណែនាំដំណោះស្រាយសេវាធានារ៉ាប់រងលើផ្នែកសុខភាពដែលមានតម្លៃសមរម្យទៅកាន់ទូទាំងប្រទេស។

AIA Cambodia នឹងបន្តផ្តល់ការគាំទ្រដល់ដៃគូយូរអង្វែងគឺ មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម តាមរយៈការឧបត្ថម្ភដល់នាយកដ្ឋានមហារីកសុដន់។ មន្ទីរពេទ្យមិនស្វែងរកប្រាក់ចំណេញមួយនេះ បានចាប់ដៃគូជាមួយ AIA Cambodia ចាប់តាំងពីក្រុមហ៊ុនចាប់ផ្តើមដំណើរការនៅកម្ពុជាមកម្ល៉េះ។ កម្មវិធីលើកកម្ពស់ការយល់ដឹងពីជំងឺមហារីកសុដន់ ដែលកកើតចេញពីភាពជាដៃគូនេះ បានក្លាយជាកម្មវិធីមានអាយុកាលវែងជាងគេបំផុតនៅកម្ពុជា ជាមួយការផ្តល់ជូនការពិនិត្យស្វែងរកជំងឺមហារីកសុដន់ដោយឥតគិតថ្លៃ ការពិនិត្យរោគវិនិច្ឆ័យ និងមធ្យោបាយផ្សេងៗសម្រាប់អ្នកជំងឺដែលមិនមានលទ្ធភាព ។

តាមរយៈយុទ្ធនាការ Fit for Hope ២០២២ នេះ AIA Cambodia នឹងគាំទ្រគំនិតផ្តួចផ្តើមទាំងនេះតាមរយៈ ផ្តល់ការពិនិត្យស្វែងរកជំងឺមហារីកសុដន់ដោយឥតគិតថ្លៃ និងវេទិកាអប់រំសុខភាពនៅតាមបណ្តាខេត្តចំនួន ៤ រួមមាន កំពត កំពង់ចាម សៀមរាប បាត់ដំបង និង ៣ទីតាំងនៅភ្នំពេញ គឺនៅមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម អគារ City Tower និង Factory Phnom Penh។

សកម្មភាពដ៏ទាក់ទាញ និងគួរឲ្យចាប់អារម្មណ៍មួយនៃយុទ្ធនាការ Fit for Hope នេះ គឺ “ដំណើរពណ៌ផ្កាឈូក” និងការប្រគំតន្ត្រីនៅទីក្រុងកោះពេជ្រ នៅថ្ងៃទី ២២ ខែតុលា ត្រូវនឹងខែដែលពិភពលោកប្រារព្ធទិវាយល់ដឹងអំពីជំងឺមហារីកសុដន់។ លើសពីនេះ បុគ្គលិក និងទីប្រឹក្សាផែនការជីវិត AIA Cambodia នឹងទទួលបានចំណេះដឹងបំប៉ន ដើម្បីទទួលយកតួនាទីថ្មី ជាបុគ្គលដ៏សំខាន់របស់យុទ្ធនាការនេះ ក្នុងការផ្សព្វផ្សាយ និងចែកចាយព័ត៌មានអំពីការយល់ដឹងនៃជំងឺមហារីកសុដន់ទៅកាន់អតិថិជន និងមហាជន។

ក្នុងកម្មវិធីនោះ **លោកជំទាវ កិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** មានប្រសាសន៍ថា៖ «ជំងឺមហារីកសុដន់សព្វថ្ងៃនេះ គឺជាជំងឺមហារីកដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញច្រើនជាងគេបំផុតក្នុងពិភពលោក ហើយដែលតួលេខអ្នកស្លាប់ភាគច្រើន

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH



ជាស្ត្រី។ គោលបំណងរបស់យើង គឺចង់ផ្តល់ការអប់រំដល់ស្ត្រីទូទាំងប្រទេស នូវវិធានការប្រយុទ្ធប្រឆាំងនឹងជំងឺនេះ ដែលផ្តល់ផលប៉ះពាល់ដល់ពួកគេមិនត្រឹមតែសុខភាពប៉ុណ្ណោះទេ ថែមទាំងផ្លូវចិត្ត និងហិរញ្ញវត្ថុផងដែរ។

“ខ្ញុំសូមកោតសរសើរដល់ក្រុមហ៊ុន AIA Cambodia មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ក្រុមការងារ និងដៃគូពាក់ព័ន្ធទាំងអស់សម្រាប់គំនិតផ្តួចផ្តើមលើយុទ្ធនាការប្រចាំឆ្នាំនេះឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងពីជំងឺមហារីកសុដន់ដល់សាធារណជន។ តាមរយៈផ្តល់ការយល់ដឹងពីគ្រោះថ្នាក់នៃជំងឺមហារីកសុដន់ និងការគាំទ្រនេះ អាចឲ្យស្ត្រីកម្ពុជាកាន់តែច្រើនទទួលបានចំណេះដឹងកាន់តែច្បាស់អំពីជំងឺនេះ ក៏ដូចជារបៀបពិនិត្យរោគវិនិច្ឆ័យឱ្យបានទាន់ពេលវេលា ដើម្បីផ្តល់ភាពងាយស្រួលក្នុងការព្យាបាល និងទទួលបានឱកាសខ្ពស់ក្នុងការជាសះស្បើយ និងសង្គ្រោះជីវិតផងដែរ។”

**លោក** Andrew Loh អគ្គនាយកប្រតិបត្តិក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA Cambodia បានលើកឡើងថា “ នេះជាកិត្តិយសដ៏ធំធេងរបស់យើងដែល Fit for Hope ក្នុងឆ្នាំនេះត្រូវបានគាំទ្រដោយក្រសួងកិច្ចការនារី។ AIA Cambodia បានចុះអនុស្សរណៈយោគយល់លើកិច្ចសហការជាមួយក្រសួងកិច្ចការនារីកាលពីខែ មេសា ឆ្នាំនេះ លើគម្រោង “លើកកម្ពស់សុខភាព និងហិរញ្ញវត្ថុសម្រាប់ស្ត្រីកម្ពុជា” ដើម្បីបង្កើនការយល់ដឹងដល់ស្ត្រី សមភាពយេនឌ័រ និងសិទ្ធិស្ត្រី។ យើងខ្ញុំសូមអរគុណអស់ពីចិត្ត ដល់ក្រសួងកិច្ចការនារីចំពោះការចូលរួមសហការ និងគាំទ្រយុទ្ធនាការនេះ ហើយយើងខ្ញុំជឿជាក់ថាតាមរយៈការជួយជ្រោមជ្រែងរបស់ក្រសួងកិច្ចការនារីនេះ នឹងជួយជម្រុញ ដល់ការបង្កើនការយល់ដឹងអំពីជំងឺមហារីកសុដន់ដល់សហគមន៍ឲ្យបានកាន់តែទូលំទូលាយ»។

“យើងខ្ញុំពិតជាមានក្តីរីករាយយ៉ាងខ្លាំងដែលរាល់កម្មវិធីចុះដល់មូលដ្ឋាន និងសកម្មភាពទាំងអស់របស់យុទ្ធនាការនេះត្រឡប់មកវិញ បន្ទាប់ពីអាក់ខានដោយសារជំងឺរាតត្បាតកូវីដ។ កត្តាទាំងនេះពិតជាជួយបង្កើតប្រសិទ្ធិភាពរយៈពេលយូរអង្វែង ដើម្បីឲ្យព័ត៌មានទាំងអស់បានទៅដល់ដៃប្រជាជនកម្ពុជាកាន់តែច្រើន និងអនុញ្ញាតឱ្យយើងខ្ញុំបានភ្ជាប់ទំនាក់ទំនងផ្ទាល់ជាមួយប្រជាជនថ្នាក់មូលដ្ឋាន ដើម្បីឲ្យប្រាកដថារាល់តម្រូវការ ឬបញ្ហាត្រូវបានពិភាក្សារវាងប្រជាជនកម្ពុជា និងបុគ្គលិក មន្ទីរពេទ្យព្រះសីហនុមន្ទីរមណ្ឌលនៃក្តីសង្ឃឹម បុគ្គលិកនិងទីប្រឹក្សាផែនការជីវិត AIA Cambodia របស់យើង»។

លោកបានបន្ថែមថា AIA Cambodia មានកិត្តិយសក្នុងការបន្តភាពជាដៃគូជាមួយមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ដែលជាមន្ទីរពេទ្យធ្វើការដោយឥតស្រាកស្រាន្តអស់រយៈពេលជិតបួនទសវត្សរ៍ដើម្បីជួយស្ត្រីកម្ពុជាប្រយុទ្ធប្រឆាំងនឹងជំងឺមហារីកសុដន់។ កិច្ចសហការនេះក៏ជួយឱ្យ AIA Cambodia សម្រេចបាននូវគោលបំណងក្នុងការជួយប្រជាជនកម្ពុជារស់ឲ្យនៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ ហើយស្របតាមគំនិតផ្តួចផ្តើម AIA One Billion របស់ AIA Group ដើម្បីជួយដល់ប្រជាជនមួយពាន់លាននាក់នៅអាស៊ីឱ្យទទួលបានសុខភាព និងជីវិតកាន់តែប្រសើរនៅឆ្នាំ ២០៣០។

“យើងខ្ញុំសូមគោរពអញ្ជើញប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រួមគ្នាផ្លុងមួយ ដើម្បីគាំទ្រដល់យុទ្ធនាការនេះ និងចូលរួមបរិច្ចាគដល់មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម។ នៅពេលយើងពួតដៃធ្វើការរួមគ្នា យើងប្រាកដជាអាចសម្រេចកិច្ចការធំៗជាច្រើន ហើយ Fit for Hope នឹងរង់ចាំអ្នកទាំងអស់គ្នាដើម្បីបង្កើតភាពជឿជាក់ ធានាថាស្ត្រីកម្ពុជាទាំងអស់នឹងទទួលបានសុខភាព និងជីវិតកាន់តែប្រសើរឡើង»។

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

ចំពោះសាធារណជន និងអ្នកដែលបានអញ្ជើញទៅវេទិកាអប់រំស្តីពីជំងឺមហារីកសុដន់នៅតាមទីតាំងខេត្ត/ក្រុងទាំងប្រាំពីរខាងលើ អាចចូលរួមបរិច្ចាគចាប់ពី 1ដុល្លារជាសាច់ប្រាក់ ឬតាមរយៈគណនីធនាគារ ABA ខាងក្រោម៖

• លេខគណនី ABA ៖ ០០៤៤០០៥៣៩
• ឈ្មោះគណនី ៖ AIA (CAMBODIA) LIFE INSURANCE PLC

សម្រាប់រាល់ការបរិច្ចាគ ៥ ដុល្លារ នឹងទទួលបានអាវយឺត ឬ ឆត្រយុទ្ធនាការ **Fit for Hope** ដើម្បីជាការថ្លែងអំណរគុណ។

ថវិកាទាំងអស់ដែលទទួលបានទាំងអស់នឹងត្រូវប្រគល់ជូនមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ដើម្បីជួយដល់ស្ត្រីកម្ពុជាដែលត្រូវការជំនួយឲ្យទទួលបានការពិនិត្យ និងការព្យាបាលជំងឺមហារីកសុដន់នេះទាន់ពេលវេលា។

សម្រាប់ព័ត៌មានបន្ថែមអំពីយុទ្ធនាការ **Fit for Hope** និងដំណោះស្រាយពី **AIA Cambodia** លើផែនការអនាគត និងការពារជំងឺធ្ងន់ធ្ងរលើគ្រួសាររបស់លោកអ្នក សូមតាមដានទំព័រហ្វេសប៊ុករបស់ **AIA Cambodia** ឬចូលទៅកាន់គេហទំព័រ aia.com.kh។

## អំពី AIA Cambodia

ក្រុមហ៊ុនធានារ៉ាប់រង **AIA Cambodia** គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។

ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ **AIA Cambodia** ធ្វើឡើងស្របតាមគោលបំណងក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ ២០១៧ យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដំបូងបង្អស់នៅកម្ពុជា ផ្តល់ការការពាររហូតដល់ ២៦ ស្ថានភាពជំងឺធ្ងន់ធ្ងរ។

ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា **AIA Cambodia** ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។

**AIA Cambodia** ផ្តោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការ ជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។

**AIA (Cambodia) Life Insurance Plc**
12th Floor, Exchange Square,
Street 106 – 61, Sangkat Wat Phnom,
Khan Daun Penh,
Phnom Penh, Kingdom of Cambodia
AIA.COM.KH

# Media Release

យើងខ្ញុំក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។

ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លឹបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លឹបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។

**AIA Cambodia** គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)" ពី HR Asia ក្នុងរយៈពេលពីរឆ្នាំជាប់គ្នា ២០២០ និង ២០២១។

**AIA Cambodia** មានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។

ព័ត៌មានបន្ថែមតាមរយៈគេហទំព័រ www.aia.com.kh។

ទំនាក់ទំនងសារព័ត៌មាន
ម៉េង ដាណែត
ប្រធានផ្នែកទំនាក់ទំនងសាធារណៈ
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
Daneth-d.Meng@aia.com